

## សេចក្តីណែនាំអំពីការប្រើប្រាស់កន្លែង

# ម្លប់សហគមន៍


រៀបចំដោយ

សិល្បៈខ្មែរអមតៈ

គាំទ្រដោយ

Debra Fram and
Eric Schwartz



# អំពី ម្លប់សហគមន៍

ក្រោមគម្រោងរួមគ្នាជាមួយអង្គការសិល្បៈខ្មែរអមតៈ (សខអ) ជំនាន់នៃភាពច្នៃប្រឌិត បានបង្កើត និងរចនាកន្លែងថ្មីមួយឈ្មោះថា ម្លប់សហគមន៍ ដើម្បីទុកជាទីប្រើប្រាស់សម្រាប់សិល្បៈសហគមន៍។ កន្លែងថ្មីនេះ បានបើកឱ្យប្រើប្រាស់នៅក្នុងខែកុម្ភៈ ឆ្នាំ ២០២៥ ដែលអាចទទួលមនុស្សបានរហូតដល់ ៨០ នាក់។

ម្លប់សហគមន៍ គឺជាកន្លែងដែលមានសុវត្ថិភាព និងភាពស្និតស្នាលសម្រាប់មនុស្សគ្រប់ៗគ្នា។ កន្លែងនេះជួយផ្តល់ជាឱកាសដល់សិល្បករ ប្រតិបត្តិករវប្បធម៌ និងសហគមន៍សិល្បៈ ដើម្បីឱ្យពួកគេបានបង្ហាញសកម្មភាពច្នៃប្រតិដ្ឋ និងសកម្មភាពវប្បធម៌ផ្សេងៗ រួមមាន បាឋកថា, ពិព័រណ៌, ការសម្តែង, ការបញ្ចាំងភាពយន្ត, វេទិកាអំណាន និងសកម្មភាពជាច្រើនទៀត រាប់បញ្ចូលទាំងកម្មវិធីផ្សេងៗទៀតរបស់ សខអ ផង។

សេចក្តីណែនាំនេះបង្កើតឡើងក្នុងគោលបំណងឱ្យអ្នកដែលចង់ប្រើប្រាស់កន្លែង ម្លប់សហគមន៍ បានយល់ច្បាស់អំពីលក្ខខណ្ឌនៃការប្រើប្រាស់ទីតាំងជាមុនសិន។

## ១ សិទ្ធិ និងសកម្មភាព

សិល្បករ ប្រតិបត្តិកវប្បធម៌ ក្រុម និងអង្គការ អាចមានសិទ្ធិដាក់សំណើស្នើសុំប្រើប្រាស់ ម្លប់សហគមន៍ បាន ។ សកម្មភាពដែលអាចធ្វើនៅ ម្លប់សហគមន៍ បានរួមមានដូចខាងក្រោម (អាចនៅមានលើសពីនេះទៀត)៖

- កម្មវិធីសម្តែងផ្ទាល់
- ពិព័រណ៍សិល្បៈសូនរូប
- សិក្ខាសាលានិងការបណ្តុះបណ្តាល
- បាឋកថា កិច្ចពិភាក្សា និងបទបង្ហាញ
- ការបញ្ចាំងភាពយន្ត
- អំណាន
- ផ្សារសហគមន៍ចុងសប្តាហ៍

## ២ ថ្ងៃ និងម៉ោងប្រើប្រាស់ទីតាំង

- ថ្ងៃធ្វើការ (ចន្ទ-សុក្រ) ៖ អាចរៀបចំបានក្រោយម៉ោង ៥:៣០ ល្ងាច រហូតដល់ម៉ោង ១០:០០ យប់ ។
- ចុងសប្តាហ៍ ៖ អាចរៀបចំបាននៅថ្ងៃសៅរ៍តែប៉ុណ្ណោះ ចាប់ពីម៉ោង ៩:០០ ព្រឹក ដល់ម៉ោង ១០:០០ យប់ (តែក៏ត្រូវគោរពតាមបទបញ្ញត្តិរបស់អាជ្ញាធរមូលដ្ឋានផងដែរ) ។

## ៣ ការដាក់សំណើ និងដំណើរការជ្រើសរើស

- សំណើត្រូវដាក់យ៉ាងហោចណាស់មួយខែមុនថ្ងៃដែលចង់រៀបចំកម្មវិធី ។
- សំណើទាំងអស់នឹងត្រួតពិនិត្យដោយគណៈកម្មការជ្រើសរើសរបស់ សខអ ។
- ព័ត៌មានអំពីលទ្ធផលស្នើសុំនឹងជម្រាបជូនក្នុងរយៈពេលប្រាំថ្ងៃនៃថ្ងៃធ្វើការ ។

## ៤ ឧបករណ៍ និងសម្ភារៈ

ក្នុងអំឡុងពេលនៃដំណើរការសាកល្បងនេះ សខអ នឹងផ្តល់ឧបករណ៍សម្ភារៈដូចខាងក្រោម៖

- ម៉ាស៊ីនបញ្ចាំង (LCD) និងអេក្រង់
- ប្រព័ន្ធសំឡេង
- ក្តារខៀន
- តុនិងកៅអី
- កន្ទេលនិងខ្នើយទ្រាប់អង្គុយ
- ម៉ាស៊ីនទឹកក្តៅទឹកត្រជាក់

ឧបករណ៍សម្ភារៈផ្សេងទៀត ម្ចាស់កម្មវិធីត្រូវទទួលខុសត្រូវរៀបចំដោយខ្លួនឯង ។
ម្ចាស់កម្មវិធីទទួលខុសត្រូវចំពោះការប្រើប្រាស់សម្ភារៈដែលបានផ្តល់ឱ្យ ឱ្យបានត្រឹមត្រូវ ។ ប្រសិនបើមានការខូចខាត សម្ភារៈណាមួយ ត្រូវផ្តល់ដំណឹងភ្លាមៗ ហើយអាចនឹងត្រូវបង់ប្រាក់សងការខូចខាតនោះ ។

## ៥ ការផ្សព្វផ្សាយអំពីកម្មវិធី

- សខអនឹងជួយផ្សព្វផ្សាយនៅលើបណ្តាញឌីជីថលរបស់ខ្លួនទៅតាមផែនការផ្សព្វផ្សាយដែលព្រមព្រៀងគ្នា។
- ម្ចាស់កម្មវិធីទទួលខុសត្រូវលើការរកទស្សនិកជន និងការលក់សំបុត្រដោយខ្លួនឯង ។
- ប្រសិនបើត្រូវការប្រើប្រាស់និមិត្តសញ្ញាឬឈ្មោះរបស់ សខអ នៅលើសម្ភារៈផ្សព្វផ្សាយរបស់កម្មវិធី ត្រូវស្នើសុំការត្រួតពិនិត្យ និងការយល់ព្រមពី សខអ ជាមុនសិន ។
- យើងស្វាគមន៍ការជួយឧបត្ថម្ភពីដៃគូនានា តែពុំមែន ពីក្រុមហ៊ុនស្រាឬបារី ឡើយ ។ ផលិតផលផ្សេងដែលស្ថិតនៅក្រោមឆ័ត្រនៃក្រុមហ៊ុនតែមួយអាចនឹងត្រូវពិចារណា ប្រសិនបើពុំមានការដាក់បង្ហាញម៉ាកយីហោ/ស្លាកសញ្ញានោះទេ។

## ៦ ក្រមសីលធម៌ និងការប្រើប្រាស់ទីតាំង

ម្លប់សហគមន៍ ជាកន្លែងប្រើប្រាស់រួមសម្រាប់សហគមន៍ ។ ដើម្បីឱ្យអ្នកគ្រប់គ្នាអាចទទួលបានបទពិសោធន៍ល្អៗ យើងសូមស្នើសុំឱ្យអ្នកប្រើប្រាស់ទាំងអស់អនុវត្តតាមក្រមសីលធម៌ដូចខាងក្រោម៖

- ត្រូវចេះគោរពទីកន្លែង ឧបករណ៍សម្ភារៈ និងអ្នកប្រើប្រាស់ដទៃទៀត ។
- ហាមមិនឱ្យមានការរំខាន ការជក់បារី ការផឹកស្រា ឬការប្រើប្រាស់សារធាតុហាមឃាត់ ។
- ម្ចាស់កម្មវិធីត្រូវរៀបចំកន្លែងឱ្យបានដូចដើមវិញ បន្ទាប់ពីបានប្រើប្រាស់រួច ។

## ៧ ក្រមសីលធម៌ និងការប្រើប្រាស់ទីតាំង

- អនុញ្ញាតឱ្យតែអាហារសម្រន់ងាយៗ និងភេសជ្ជៈប៉ុណ្ណោះ ។
- មិនអាចប្រើឧបករណ៍ចំអិនឬកម្តៅឡើយ ។
- ម្ចាស់កម្មវិធីត្រូវសម្អាត និងចោលសម្រាមឱ្យបានត្រឹមត្រូវ ក្រុមការងារ សខអ អាចជួយបានបើត្រូវការ ។
- ត្រូវយកចិត្តទុកដាក់ថែរក្សាបរិស្ថាន

## ៨ ការទុកដាក់ឥវ៉ាន់ និងការទទួលខុសត្រូវ

- រាល់ការទុកដាក់សម្ភារៈកម្មវិធីជាបណ្តោះអាសន្ន មិនអាចលើសពី ២៤ ម៉ោងឡើយនៅមុន និងក្រោយកម្មវិធី ។ ករណីនេះ អាចប្រែប្រួលទៅតាមការព្រមព្រៀងគ្នា ។
- សខអ មិនទទួលខុសត្រូវចំពោះការបាត់បង់ឬខូចខាតទ្រព្យសម្បត្តិផ្ទាល់ខ្លួនដែលទុកចោលនៅក្នុងបរិវេណ ម្លប់សហគមន៍ ទេ ប៉ុន្តែយើងនឹងជួយរកឱ្យអស់ពីលទ្ធភាព ។

## ៩ ចំណតរថយន្ត

អំឡុងពេលមានកម្មវិធី ម្លប់សហគមន៍ពុំមានទីសម្រាប់ចតយានជំនិះឡើយ ។ អ្នកចូលរួមកម្មវិធីត្រូវយកយានជំនិះរបស់ខ្លួនទៅចតនៅទីតាំងណាមួយខាងក្រោមនេះ

- ផ្សារអ៊ីអនមួយ
- វត្តស្វាយពពែ

## ១០ អាសយដ្ឋានទំនាក់ទំនង និងការដាក់សំណើ

ចំពោះសំណួរនិងការដាក់សំណើ សូមទាក់ទង៖

admin@cambodianlivingarts.org
+៨៥៥ ២៣ ៩៨៦ ០៣២

សម្រាប់ព័ត៌មានបន្ថែម អ្នកអាចចូលទៅមើលនៅលើ៖

Cambodian Living Arts (CLA)
cambodianlivingarts
Cambodian Living Arts
Cambodian Living Arts
CambodianLivingArts
artsopportunity

# ១១ រូបថតកម្មវិធីពីមុន និងឧបករណ៍/សម្ភារៈ




























ពីក្រុមការងារអង្គការសិល្បៈខ្មែរអមតៈទាំងអស់ យើងរង់ចាំទទួលស្វាគមន៍អ្នកនៅ

**ម្លប់សហគមន៍**

កន្លែងសម្រាប់ភាពច្នៃប្រតិដ្ឋ, សហគមន៍

និងទំនាក់ទំនងវប្បធម៌!